នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Feb-2011, 14:14
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ:

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្ដីសង្ខេបរបស់សហព្រះរាជអាជ្ញា នៅលើញត្តិរបស់ អៀង សារី**
**សុំការណែនាំអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

លោក អាង ឧត្ដម

លោក Michael G.KARNAVAS

លោក ផាត់ ពៅសៀង

កញ្ញា Diana ELLIS QC

លោក សរ សុវ៉ាន

លោក Jacques VERGÈS

លោក Phillipe GRECIANO

១. នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ជនជាប់ចោទ អៀង សារី ("ជនជាប់ចោទ") បានដាក់ញត្តិមួយស្នើសុំការណែនាំ អំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី[1]។ ក្នុងញត្តិនេះ ជនជាប់ចោទបានអះអាងដោយសន្ទតជាមុនថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវរបស់គាត់ - ជាពិសេសសិទ្ធិសមភាពនៃមធ្យោបាយតទល់គ្នា និងសិទ្ធិត្រូវបានជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ - អាចនឹងត្រូវអន្តរាយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនអនុម័តការណែនាំនៅមុនពេលចាប់ផ្តើមសវនាការ ដើម្បីបញ្ជាក់បំភ្លឺអំពីតួនាទីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី[2]។ ទាក់ទិននឹងកង្វល់នេះ ជនជាប់ចោទបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណា និងពិភាក្សាលើសំណើប្រាំមួយនៅក្នុងពេលប្រជុំស្តីពីការរៀបចំសវនាការដែលនឹងចូលមកដល់ខាងមុខនេះ[3]។

២. សហព្រះរាជអាជ្ញា សូមធ្វើការសង្កេតទៅលើសំណើស្នើឡើងទាំងនេះ ដូចតទៅ៖

(១) *<u>សំណើ # ១:</u> - កំណត់ព្រំដែននៃការអន្តរាគមន៍ចំពោះតែបញ្ហាណាដែលរួមចំណែកដល់ការពិត:* សហព្រះរាជអាជ្ញា កត់សំគាល់ថា ស្របតាមគោលបំណងរួមជាមូលដ្ឋាននៃដំណើរការនីតិវិធីរបស់ អ.វ.ត.ក ដូចបានឆ្លុះបញ្ចាំងនៅក្នុងវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក - គឺគ្រប់ភាគី *ទាំងអស់* មិនមែនតែភាគីដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះទេ ដែលមានកាតព្វកិច្ចកំណត់ព្រំដែនលើការដាក់សារណាចំពោះបញ្ហាផ្សេងៗ ដែលនឹងរួមចំណែកដល់ការស្វែងរកការពិត[4]។

(២) *<u>សំណើ # ២:</u> - កំណត់ព្រំដែននៃការអន្តរាគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហានានាដែលពាក់ព័ន្ធទាំងការចោទប្រកាន់ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្រាប់តែគោលបំណងនៃការបង្កើតភស្តុតាងដែលបញ្ជាក់ពីព្យសនកម្ម :* សហព្រះរាជអាជ្ញា សូមកត់សំគាល់ថា នៅពេលដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីនានា មិនអាចដើរតួនាទីជាព្រះរាជអាជ្ញាបន្ថែមនោះ វិធាន២៣ នៃវិធានផ្ទៃក្នុងចែងថា តួនាទីមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុង អវតក គឺ "គាំទ្រដល់ការចោទប្រកាន់"។ នេះគឺមានន័យថា

---

[1] ញត្តិរបស់ អៀង សារី សុំការណែនាំអំពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ, ២៤ មករា ២០១១, E23 (ចាប់ពីនេះតទៅហៅថា "ញត្តិស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់ អៀង សារី") ។

[2] ញត្តិស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់ អៀង សារី, កថាខ័ណ្ឌទី៩ ។

[3] ញត្តិស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់ អៀង សារី, កថាខ័ណ្ឌទី២១ ។

[4] *សូមអាន* វិធាន៨៥ នៃវិធានផ្ទៃក្នុងសម្រាប់ អវតក ("[ប្រធានអង្គជំនុំជម្រះ] ត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តទៅបានដោយសេរី ។ ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត ។ *សូមអានផងដែរ* វិធាន ៥៥.៥, ៦០, ៨៧ និង ៩១.៣ ។ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ, អង្គជំនុំជម្រះសាលាដំបូង, ៩ តុលា ២០០៩, E៩២/៣, (ចាប់ពីនេះតទៅហៅថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"), កថាខ័ណ្ឌទី២១, ២៥ ។

ភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយ មានសិទ្ធិអាចផ្ដល់ភស្ដុតាងដែលទាក់ទងនឹងបទចោទប្រកាន់ ស្ថិតនៅជាកម្មវត្ថុនៃតួនាទីដ៏ចំបងរបស់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញភស្ដុតាងអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ[5]។

(៣) *សំណើ # ៣: - កំណត់ព្រំដែននៃការអន្តរាគមន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីលើបញ្ហានានា ដែលមិនស្របជាមួយសិទ្ធិរបស់ជនចាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងឥតលំអៀង:* សហព្រះរាជអាជ្ញា សូមធ្វើការកត់សំគាល់ថា វិធានផ្ទៃក្នុង អវតក បានឆ្លុះបញ្ចាំងរួចហើយអំពីគោលការណ៍នេះ និងបានបង្ហាញភស្ដុតាងថា រាល់ការដាក់សារណារបស់ភាគីទាំងអស់ គឺត្រូវបានបញ្ញត្តិដោយអង្គជំនុំជម្រះសាលាដំបូង ដោយចងចាំនៅក្នុងចិត្តអំពីផលប្រយោជន៍នេះ[6]។

(៤) *សំណើ # ៤: - កំណត់ព្រំដែននៃការអន្តរាគមន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅត្រឹមបញ្ហានានាដែលនឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានដែលជ្រុលហួសហេតុ ទៅលើភាពឆាប់រហ័សនៃដំណើរការនីតិវិធី៖* ជាថ្មីម្ដងទៀត សហព្រះរាជអាជ្ញាជឿជាក់ថា វិធានផ្ទៃក្នុងបានដាក់បញ្ចូលយ៉ាងគ្រប់គ្រាន់នូវសញ្ញាណដែលថា ដំណើរការនីតិវិធីជំនុំជម្រះត្រូវតែបានធ្វើឡើងឲ្យបានឆាប់រហ័ស[7]។ ពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាជឿជាក់ថា វិធាននានាដែលបានធ្វើវិសោធនកម្មរួចហើយ ស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី - ដោយឡែក ការបង្កើតឲ្យមានក្រុមដើមបណ្ដឹងរដ្ឋប្បវេណីបង្រួមចូល គ្នាតែមួយ ដែលតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី[8] - បានផ្ដល់នូវការធានាយ៉ាងគ្រប់គ្រាន់ថា ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នឹងមិនមានទំនាស់ជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវដំណើរការនីតិវិធីដ៏ឆាប់រហ័សមួយនោះឡើយ។

(៥) *សំណើ #៥ និង #៦: - ដាក់កម្រិតលើដើមបណ្ដឹងរដ្ឋប្បវេណី មិនឲ្យធ្វើសារណាស្ដីពីការផ្ដន្ទាទោស និងដាក់កម្រិតលើដើមបណ្ដឹងរដ្ឋប្បវេណី មិនឲ្យសួរសាក្សី អ្នកជំនាញ ឬជនជាប់ចោទ ដើម្បីសាកសួរអំពីអត្តចរិតរបស់ជនជាប់ចោទក្នុងគោលបំណងនៃការផ្ដន្ទាទោស៖* សហព្រះរាជអាជ្ញា កត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ធ្លាប់បាន

---

[5] *សូមអាន* វិធានផ្ទៃក្នុង អវតក វិធាន ៨៧.១ ។

[6] *សូមអាន* វិធានផ្ទៃក្នុង អវតក វិធាន២១, និងវិធាន ៨៥ ។

[7] *សូមមើល, ជាឧទាហរណ៍* វិធានផ្ទៃក្នុង អ.វ.ត.ក, វិធាន១២*ស្ទួនពីរ*, ២១, ៣៧, ៧៩.៧ ។

[8] *សូមមើល* វិធានផ្ទៃក្នុង អ.វ.ត.ក, វិធាន១២*ស្ទួនពីរ* ("សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវធានាឲ្យមានប្រសិទ្ធភាពអំពីការរៀបចំការតំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដែលធ្វើឲ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អ.វ.ត.ក") ។ *សូមមើលផងដែរ ដូចគ្នាដែល,* វិធាន ២៣.៣ ។

បញ្ជាក់ទស្សនៈរបស់ខ្លួនអំពីបញ្ហាទាំងនេះយ៉ាងច្បាស់លាស់រួចហើយ[9]។ ដូច្នេះ ការប្រកាសឱ្យប្រើនូវគោលការណ៍ជាក់លាក់ទាំងនោះ ហាក់ដូចជាពុំចាំបាច់ទេ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាជឿជាក់ថា សំណួរនានាស្តីពី៖ ក) តើអ្វីខ្លះបង្កើតបានជាសក្ខីកម្មទាក់ទងទៅនឹងការផ្តន្ទាទោសដែលជាការផ្ទុយទៅនឹងពិរុទ្ធភាព ឬ ភាពស្លូតត្រង់របស់ជនជាប់ចោទ, និង ខ) តើអ្វីខ្លះបង្កើតបានជាសក្ខីកម្មទាក់ទងទៅនឹងអត្តចរិត ដែលជាបញ្ហានៅក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវកំណត់បានយ៉ាងល្អប្រសើរបំផុត ក្នុងអំឡុងពេលនៃដំណើរការនីតិវិធី។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

[9] *សូមមើល,* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី ២៨-៤០, ៤៤-៤៨ ។